ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីប្រកាសព័ត៌មាន

នៅព្រឹកថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧ នៅសណ្ឋាគារសូហ្វីតែលភូកេត្រា រាជធានីភ្នំពេញ **ឯកឧត្តម បណ្ឌិត អ៊ិត សំហេង** រដ្ឋមន្រ្តីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានទទួលជួបពិភាក្សាការងារថ្នាក់រដ្ឋមន្រ្តីលើកទី២ ជាមួយ **ឯកឧត្តម** **Dato' Sri Richard Riot Anak Jaem** រដ្ឋមន្រ្តីក្រសួងធនធានមនុស្សនៃប្រទេសម៉ាឡេស៊ី ដើម្បីពិភាក្សាលើការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃប្រទេសទាំងពីរស្តីពីការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ។

ក្នុងជំនួបនៃកិច្ចប្រជុំនេះ ភាគីទាំងពីរបានសម្តែងនូវការពេញចិត្តយ៉ាងខ្លាំង ចំពោះលទ្ធផលផ្លែផ្កានៃកិច្ចសហប្រតិបត្តិការកន្លងមក។ ទន្ទឹមនឹងនេះ ភាគីទាំងពីរក៏បានឯកភាព និងជំរុញការបង្កើនល្បឿនលើការអនុវត្ត អនុស្សរណៈដែលបានចុះហត្ថលេខារួចដូចតទៅ៖

- ការអនុវត្តនីតិវិធីប្រតិបត្តិការពិសេស (SOP) ដែលក្រុមបច្ចេកទេសបានឯកភាពគ្នាឱ្យកាន់តែមានប្រសិទ្ធភាព។
- ការលើកកម្ពស់ និងការពារសិទ្ធិពលករតាមរយៈការអប់រំណែនាំតម្រង់ទិស និងការបណ្តុះបណ្តាលជំនាញហាត់ការ។
- ពង្រឹងប្រសិទ្ធភាពក្នុងការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរ។
- ការផ្លាស់ប្តូរបទពិសោធន៍ ព័ត៌មាន និងជំនាញបច្ចេកទេស និងវិជ្ជាជីវៈ។
- ការផ្លាស់ប្តូរព័ត៌មាន ដើម្បីទប់ស្កាត់ការជ្រើសរើស និងប្រើប្រាស់ពលករខុសច្បាប់ក៏ដូចជាការបង្ការ និងប្រយុទ្ធប្រឆាំងការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការជួញដូរមនុស្ស។
- ផ្នែកផ្សេងទៀត នៃកិច្ចសហប្រតិបត្តិការដែលភាគីទាំងពីរ បានព្រមព្រៀងគ្នា។

ភាគីទាំងពីរបានឯកភាពជំរុញឱ្យក្រុមការងារបច្ចេកទេសនៃប្រទេសទាំងពីរ ប្រជុំពិភាក្សាបញ្ចប់រាល់បញ្ហាដែលនៅសេសសល់បានចប់សព្វគ្រប់ នៅក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសលើកទី៣ ឱ្យបានមុនដំណាច់ខែឧសភា ឆ្នាំ២០១៧ នេះ។

ភាគីម៉ាឡេស៊ីបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះរាជរដ្ឋាភិបាលកម្ពុជាដែលបានបើកឱ្យដំណើរការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ីឡើងវិញ។ ទន្ទឹមនឹងនេះ ភាគីកម្ពុជាក៏បានថ្លែងអំណរគុណចំពោះភាគីម៉ាឡេស៊ី ដែលបានអនុញ្ញាតឱ្យពលករដែលមិនទាន់ស្របច្បាប់ អាចរៀបចំបែបបទស្របច្បាប់ ដើម្បីរស់នៅ និងធ្វើការដោយស្របច្បាប់។ ជាមួយគ្នានេះ ភាគីម៉ាឡេស៊ី បានអញ្ជើញឯកឧត្តមរដ្ឋមន្រ្តី ដើម្បីដឹកនាំគណៈប្រតិភូ ដើម្បីបំពេញទស្សនកិច្ចនៅប្រទេសម៉ាឡេស៊ី តាមពេលវេលាសមស្របមុនដំណាច់ឆ្នាំ២០១៧។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

សូមបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជា បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលម៉ាឡេស៊ី ស្តីពីការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៥។ បន្ទាប់ពីការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នានេះ ក្រុមការងារបច្ចេកទេសនៃប្រទេសទាំងពីរបានជួបពិភាក្សាគ្នាចំនួន ២លើក ដើម្បីពិភាក្សាលើការរៀបចំនីតិវិធីសម្រាប់ជ្រើសរើស និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី កាលពីថ្ងៃទី១៨-១៩ ខែកក្កដា ឆ្នាំ២០១៦ នៅរាជធានីភ្នំពេញ និងនៅថ្ងៃទី៣០ ខែវិច្ឆិកា និងថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៦ នៅ Putra Jaya ប្រទេសម៉ាឡេស៊ី។

**រាជធានីភ្នំពេញ ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧**